# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករបរធនបាលកិច្ច**

លេខ: ០២៥/២៣ ... ន.ប.ធ./ស.ជ.ណ.

ថ្ងៃ ពុធ ៨រោច ខែ ទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្តល់អាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចដល់ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក

**និយ័តករបរធនបាលកិច្ច (ន.ប.ធ.)** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ធនាគារ **ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក** ទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ចសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម ដោយបានបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់គ្រាន់តាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានក្នុងវិស័យបរធនបាលកិច្ច។

បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ ដែលមានបំណងប្រើប្រាស់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ចសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម អាចទំនាក់ទំនងទៅកាន់ធនាគារ **ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក**។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម បរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច បរធនបាល បុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

**និយ័តករបរធនបាលកិច្ច**

អាសយដ្ឋាន : អគារ ១៦៨F (ជាន់ទី៨) ផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamres 1, Khan Russey Keo, Phnom Penh, Kingdom of Cambodia
ទូរសព្ទ : (+៨៥៥)២៣-២៣៧-៨៨៨
សារអេឡិចត្រូនិច : info@trustregulator.gov.kh
គេហទំព័រ : www.trustregulator.gov.kh